គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

# វេទិការៀនសូត្រស្តីពីការគ្រប់គ្រងធនធានមនុស្សលើកទី ៥២

## ក្រោមប្រធានបទ “ការបង្កើត និងវាយតម្លៃបទពណ៌នាការងារ និងការគណនាអត្ថប្រយោជន៍នានានៃសំណងសម្រាប់បុគ្គលិក”

ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០២៥
ម៉ោង ៨:០០ ដល់ ៥:០០ ល្ងាច
តាមរយៈការចូលរួមផ្ទាល់ និងតាមប្រព័ន្ធអនឡាញ **Zoom Meeting**
**ទីតាំងភោជនីយដ្ឋានទន្លេបាសាក់២**

## ១. សេចក្តីផ្តើម

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គសក) ជាអង្គការសមាជិកភាពដ៏ធំ និងមានវ័យចំណាស់ជាងគេមួយនៅក្នុងប្រទេសកម្ពុជា។ ក្នុងឆ្នាំ២០២៥ អង្គការ គសក មានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសចំនួនជិត២០០ស្ថាប័ន។ បច្ចុប្បន្ននេះ អង្គការ គសក បានកំពុងអនុវត្តកម្មវិធីមជ្ឈមណ្ឌលអភិបាលកិច្ចដំណាក់កាលទី៥ ពីឆ្នាំ២០២៤ ដល់ ២០២៨។ កម្មវិធីនេះ មានគោលបំណងសំខាន់គឺពង្រឹងអង្គការសង្គមស៊ីវិលតាមរយៈការធ្វើអោយប្រសើរឡើងនូវបរិយាកាសអំណោយផល និងលំហប្រជាធិបតេយ្យ។

ការបង្កើត និងវាយតម្លៃបទពណ៌នាការងារក៏ដូចជាការកំណត់ចំពោះសមិទ្ធផលការងារនៃបុគ្គលិក គឺជាវិធីសាស្រ្តដែលថ្នាក់ដឹកនាំស្ថាប័ននីមួយៗត្រូវគិតគូពីភាពច្បាស់លាស់ និងអាចអនុវត្តបានសម្រាប់ធ្វើការវាយតម្លៃលើលទ្ធផលការងាររបស់និយោជិក។ ទន្ទឹមនឹងនោះ ការទូទាត់សំណងដោយត្រឹមត្រូវ និងអនុលោមតាមច្បាប់ស្តីពីការងារក្នុងព្រះរាជាណាចក្រកម្ពុជា ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវាអាចចូលរួមចំនែកដល់ការរក្សាទំនាក់ទំនងល្អ ការគោរពគ្នារវាងបុគ្គលិក និងអ្នកគ្រប់គ្រង ហើយក៏អាចរួមចំនែកផងដែរ ក្នុងការបំពេញការងារប្រកបដោយការទទួលខុសត្រូវខ្ពស់របស់បុគ្គលិក ព្រោះវាជាផ្នែកមួយនៃការលើកទឹកចិត្តបុគ្គលិក ពិសេសជាងនេះទៅទៀត វាជួយកាត់បន្ថយនូវពេលវេលាដោះស្រាយបញ្ហានៅពេលមានការប្តឹងផ្តល់គ្នារវាងបុគ្គលិក និងអ្នកគ្រប់គ្រងអំពីការទូទាត់សំណង ហើយទាំងអស់នេះ វារួមចំនែកដល់ការលើកកម្ពស់ការអនុវត្តច្បាប់ស្តីពីការងារផងដែរ។

នៅក្នុងវេទិការៀនសូត្រផ្នែកការគ្រប់គ្រងធនធានមនុស្សលើកទី៥១ អ្នកចូលរួមបានស្នើសុំប្រធានបទពាក់ព័ន្ធនឹងការគណនាបន្ថែមទៀតលើសំណង និងអត្ថប្រយោជន៍នានាដែលបុគ្គលិកនឹងទទួលបានក្រោយពេលបញ្ចប់កិច្ចសន្យាការងារ និងទៅតាមប្រភេទនៃកិច្ចសន្យាការងាររួមទាំងវិធីសាស្រ្តនៃការវាស់វែងលទ្ធផលការងាររបស់បុគ្គលិកផងដែរ។

ដូច្នេះ អង្គការគសក នឹងរៀបចំវេទិការៀនសូត្រស្តីពី **"ការបង្កើត និងវាយតម្លៃបទពណ៌នាការងារ និងការគណនាអត្ថប្រយោជន៍នានានៃសំណងសម្រាប់បុគ្គលិក"** ដែលវេទិកានេះ នឹងប្រព្រឹត្តឡើងនាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៥ នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ និងតាមរយៈអនឡាញហ្ស៊ូម។

## ២. គោលបំណងនៃវេទិការៀនសូត្រ

ក្នុងរយៈពេលមួយថ្ងៃពេញនាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៥ អង្គការសង្គមស៊ីវិលនឹងបាន៖

1. ស្វែងយល់ពីវិធីសាស្ត្រនៃការបង្កើត និងវាយតម្លៃបទពណ៌នាការងាររបស់បុគ្គលិក
2. ស្វែងយល់បន្ថែមលើការគណនាប្រាក់ខែ និងប្រាក់បំណាច់
3. ពង្រីកទំនាក់ទំនងក្នុងចំណោមអ្នកកាន់តួនាទីផ្នែកគ្រប់គ្រងធនធានមនុស្ស។

## ៣. អ្នកចូលរួម និងការកំណត់តម្លៃនៃការចូលរួមក្នុងវេទិការៀនសូត្រ

វេទិកានេះ ត្រូវបានរៀបចំឡើងសម្រាប់ អ្នកជំនាញវិជ្ជាជីវៈ និងអ្នកប្រតិបត្តិការគ្រប់គ្រងធនធានមនុស្ស ដែលអញ្ជើញមកពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា។

- **ការចូលរួមដោយផ្ទាល់**
  - **សម្រាប់អង្គការសមាជិករបស់ គសក នឹងត្រូវបានផ្តល់ជូន ០២ កន្លែង សម្រាប់អង្គការសមាជិកនីមួយៗ បើមកលើសពីការកំណត់នឹងតម្រូវអោយបង់បដិភាគ២៥$/ម្នាក់។**
  - **អង្គការមិនមែនសមាជិក តម្រូវអោយបង់បដិភាគ៥០$/ម្នាក់សម្រាប់ការចូលរួមដោយផ្ទាល់ (ក្នុងករណីមាននៅសល់កន្លែង)។**
- **ការចូលរួមតាមរយៈប្រព័ន្ធអនឡាញហ្ស៊ូម (Zoom)**
  - ផ្តល់ជូន ០២ កន្លែងសម្រាប់សមាជិករបស់អង្គការ គ.ស.ក។ បើមកលើសពីការកំណត់នឹងតម្រូវអោយបង់បដិភាគ១០$/ម្នាក់។
  - សម្រាប់អង្គការមិនមែនសមាជិកតម្រូវអោយបង់បដិភាគ២០$/ម្នាក់សម្រាប់ការចូលរួមតាមអនឡាញ។

**សម្គាល់៖** ចំនួនមានកំណត់ សូមចុះឈ្មោះជាមុនតាមរយៈតំណរចុះឈ្មោះដែលបានផ្តល់ជូនខាងក្រោម។

https://www.ccc-cambodia.org/en/resources/event-calendar/2025-09-30/hr-learning-forum-12

## ៤. របៀបចុះឈ្មោះ

អ្នកចូលរួមទាំងអស់តម្រូវឲ្យចុះឈ្មោះជាមុន ដើម្បីកំណត់ពីការអញ្ជើញចូលរួមដោយផ្ទាល់ ឬដើម្បីអាចទទួលបានតំណរទៅកាន់វេទិការៀនសូត្រ (Zoom Link) ពីក្រុមការងារ អង្គការ គ.ស.ក សម្រាប់អ្នកចូលរួមតាមប្រព័ន្ធអនឡាញ។ តំណរ (Zoom Link) នឹងផ្ញើជូន អ្នកដែលបានចុះឈ្មោះ និងបំពេញតាមលក្ខខណ្ឌតែប៉ុណ្ណោះ (មួយថ្ងៃ មុនវេទិការៀនសូត្រចាប់ផ្តើម)។

## ៥. របៀបវារៈ

| ម៉ោង | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:០០ -០៨:៣០ | ការចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ គសក |
| ០៨:៣០-០៨:៤០ | - ការណែនាំពី បទបញ្ញាផ្ទៃក្នុងសម្រាប់វេទិការៀនសូត្រ<br>- គោរពភ្លេងជាតិ<br>- ប្រកាសគោលបំណងវេទិការៀនសូត្រ | **អ្នករៀបចំកម្មវិធី**<br>អង្គការ គសក |
| ០៨:៤០-៩:០០ | កិច្ចស្វាគមន៍ និងបើកកម្មវិធីដោយតំណាងអង្គការ គ.ស.ក | អង្គការ គសក |
| ៩:០០ -១០:០០ | **<u>បទបង្ហាញស្តីពីៈ</u>** ការបង្កើត និងវាយតម្លៃបទពណ៌នាការងារ<br>១) ការបង្កើត បទពណ៌នាការងារ | **លោកសេង សារុធ**<br>ប្រធានគ្រប់គ្រងទូទៅ<br>នៃក្រុមហ៊ុន VCA |
| ១០:០០ -១០:១៥ | **ការថតរូបជុំគ្នា និងសម្រាកពិសារអាហារសម្រន់** | |
| ១០:១៥ -១២:០០ | **<u>បន្តបទបង្ហាញស្តីពីៈ</u>** ការបង្កើត និងវាយតម្លៃបទពរនាការងារ<br>២) ការវិភាគលើ បទពណ៌នាការងារ<br>៣) ទ្រឹស្តី វាយតំលៃ បទពណ៌នាការងារ<br>*(សំណួរនិងចម្លើយ)* | **លោកសេង សារុធ**<br>ប្រធានគ្រប់គ្រងទូទៅ<br>នៃក្រុមហ៊ុន VCA |
| ១២:០០-១:៣០ | **ពិសារអាហារថ្ងៃត្រង់រួមគ្នា** | |
| ១:៣០-៣:០០ | **<u>ការធ្វើបទបង្ហាញពីការគណនាសំណង និងអត្ថប្រយោជន៍នានាៈ</u>**<br>- **របៀបគណនាប្រាក់បៀវត្សប្រចាំខែ**<br>**<u>ការបែងចែកក្រុមអនុវត្តផ្ទាល់</u>** | **លោក អ៊ុំ សាអន**<br>ប្រធានផ្នែកប្រតិបត្តិ<br>នៃអង្គការគសក |
| ៣:០០-៣:១៥ | **សម្រាកអាហារសម្រន់** | |
| ៣:១៥-៣:៣០ | **ការធ្វើការវាយតម្លៃវគ្គ** | |
| ៣:៣០-៤:៤០ | **<u>ការធ្វើបទបង្ហាញពីៈ</u>**<br>- ការគណនាប្រាក់បំណាច់បញ្ចប់កិច្ចសន្យា<br>**<u>ការបែងចែកក្រុមអនុវត្តផ្ទាល់</u>** | **លោក អ៊ុំ សាអន**<br>ប្រធានផ្នែកប្រតិបត្តិ<br>នៃអង្គការគសក |
| ៤:៤០-៥:០០ | បិទកម្មវិធី | |

***<u>កំណត់សម្គាល់:</u>*** *អង្គការ គ.ស.ក សូមរក្សាសិទ្ធិផ្លាស់ប្តូរ ឬ កែប្រែរបៀបវារៈនៃកម្មវិធីក្នុងករណីចាំបាច់។ អង្គការ គសក នឹងយករូបថតនៃវេទិការៀនសូត្រនេះសម្រាប់ការប្រើប្រាស់ផ្លូវការផ្សេងៗ។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់* *raingsey.roeung@ccc-cambodia.org*